**មូលនិធិគន្ធបុប្ផាកម្ពុជា**

លេខ :..................ម.គ.ក........

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ ចន្ទ ១១ កើត ខែ ភទ្របទ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១៩*

## សេចក្តីប្រកាសព័ត៌មាន

## ស្តីពីពិធីជួបសំណេះសំណាល និងប្រគល់-ទទួលថវិកាបរិច្ចាគជូនមូលនិធិគន្ធបុប្ផាកម្ពុជា រវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន និង ស្ថាបនិក និងប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ជីប ម៉ុង

នាព្រឹកថ្ងៃចន្ទ ១១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ នេះនៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាបរធនបាលនៃ "**មូលនិធិគន្ធបុប្ផាកម្ពុជា**" បានទទួលជួបសំណេះសំណាលជាមួយ **លោកជំទាវឧកញ៉ា ភាព ហៀក** ស្ថាបនិកក្រុមហ៊ុន ជីប ម៉ុង និង**លោកឧកញ៉ា លាង ឃុន** ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ជីប ម៉ុង និងក្រុមគ្រួសារ ព្រមទាំងសហការី ដែលបាននាំមកនូវថវិកាសប្បុរសធម៌ចំនួន ៥០០,០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក បរិច្ចាគជូន "**មូលនិធិគន្ធបុប្ផាកម្ពុជា**" ដែលជាការចូលរួមបរិច្ចាគលើកទី ២ របស់ក្រុមហ៊ុន ជីប ម៉ុង ។ ការចូលរួមបរិច្ចាគនេះ ជាកាយវិការដ៏សប្បុរសធម៌ ឆ្លើយតបចំពោះការអំពាវនាវ និងលើកទឹកចិត្តរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានបំផុសចលនាផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យបន្តផ្តល់វិភាគទានសប្បុរសធម៌ តាមរយៈការចូលរួមជាសមាជិក **មូលនិធិគន្ធបុប្ផាកម្ពុជា** ក្នុងស្មារតី និងសាបព្រោះនូវគុណធម៌ "**ខ្មែរ ជួយ ខ្មែរ**" ។

ក្នុងនាមប្រធានក្រុមប្រឹក្សាបរធនបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន** បានលើកឡើងអំពីសវតានៃការបង្កើត **មូលនិធិគន្ធបុប្ផាកម្ពុជា** និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរដល់ **លោកជំទាវឧកញ៉ា ភាព ហៀក** និង **លោកឧកញ៉ា លាង ឃុន** ចំពោះការផ្តល់វិភាគទានដ៏សប្បុរសធម៌ **ជូនមូលនិធិគន្ធបុប្ផាកម្ពុជា** នេះ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានរំលឹកអំពីការចូលរួមចំណែករបស់ **មូលនិធិគន្ធបុប្ផាស្វីស** និងគុណបំណាច់ ដែលមិនអាចកាត់ថ្លៃបានរបស់លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត Beat Richner ផងដែរ ។ ដោយប្រកាន់ខ្ជាប់នូវស្មារតី និងគុណធម៌ "**ខ្មែរ ជួយ ខ្មែរ**" **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានអំពាវនាវ និងបន្តលើកទឹកចិត្តថ្នាក់ដឹកនាំក្រុមហ៊ុន ជីប ម៉ុង

ឱ្យចូលរួមអំពាវនាវ និងបំផុសឱ្យមានការចូលរួមបន្ថែមទៀត ជាពិសេសពីសំណាក់បុគ្គលិកគ្រប់ជាន់ថ្នាក់របស់ក្រុមហ៊ុន ដើម្បីក្លាយជាសមាជិកគាំទ្ររបស់ **មូលនិធិគន្ធបុប្ផាកម្ពុជា** ទៅតាមលទ្ធភាពដែលអាចធ្វើបាន ។

ជាការឆ្លើយតប **លោកឧកញ៉ា លាង ឃុន** បានសម្តែងការកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែគិតគូរអំពីសុខទុក្ខរបស់ប្រជាពលរដ្ឋ និងជាពិសេស ការគិតគូរអំពីសុខុមាលភាពរបស់កុមារ តាមរយៈការបង្កើត **មូលនិធិគន្ធបុប្ផាកម្ពុជា** នេះឡើង ដើម្បីចូលរួមធានានិរន្តរភាពរបស់មន្ទីរពេទ្យគន្ធបុប្ផា ។ **លោកឧកញ៉ា** ក៏បានសម្តែងនូវសេចក្តីសោមនស្សរីករាយ ដែលបានរួមចំណែកក្នុងការគាំទ្រដល់ការគិតគូររបស់រាជរដ្ឋាភិបាលក្នុងការងារមនុស្សធម៌នេះ។

ជាចុងបញ្ចប់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណ និងកោតសរសើរជាថ្មីម្តងទៀត ចំពោះកាយវិការមនុស្សធម៌ និងការប្តេជ្ញាចិត្តរបស់ **លោកជំទាវឧកញ៉ា** និង **លោកឧកញ៉ា** និងបានលើកទឹកចិត្តដល់សាធារណជន និងបណ្តាក្រុមហ៊ុនដទៃទៀត ឱ្យបន្តចូលរួមគាំទ្រ **មូលនិធិគន្ធបុប្ផាកម្ពុជា** ដើម្បីធានាបាននូវនិរន្តរភាពរបស់មន្ទីរពេទ្យគន្ធបុប្ផាទាំង ០៥ ទីតាំងនៅព្រះរាជាណាចក្រកម្ពុជា និងដើម្បីភាពញញឹមរបស់កុមារដែលជាអនាគតដ៏ភ្លឺស្វាងរបស់កម្ពុជា ។